ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកសិកម្ម

# គោលការណ៍ណែនាំ
# ស្តីពី
# ការអនុវត្តកសិកម្មល្អ(GAP)

# ម្ទេសដៃនាង




រៀបចំដោយ៖

នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

ឆ្នាំ២០២២

## ព័ត៌មានបោះពុម្ព

**និពន្ធ/ចងក្រងដោយ**
**នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

អគារ៥៤B/៤៩F ផ្លូវលេខ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣

ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ៖ ០២៣ ៨៨៣ ៤២៧
I https://gda.maff.gov.kh/
F https://www.facebook.com/gda.maff.gov.kh

**គាំទ្រថវិកាសម្រាប់ការបោះពុម្ព**
**Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH**

ការិយាល័យចុះបញ្ជី៖ Bonn and Eschborn, Germany

គម្រោង៖ លើកកម្ពស់ខ្សែច្រវ៉ាក់តម្លៃកសិកម្មប្រកបដោយនិរន្តរភាពក្នុងតំបន់អាស៊ាន (ASEAN-AgriTrade)

**កម្ពុជា**
ការិយាល័យ GIZ ASEAN Regional Economic Integration មជ្ឈមណ្ឌលពាណិជ្ជកម្ម Delano ជាន់ទី៣ មហាវិថីសាធារណៈឆែក (១៦៩) កែងផ្លូវលេខ ១៣៤ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ (១២២៥៣) ប្រទេសកម្ពុជា

## សេចក្តីអះអាង

ទស្សនៈនិងយោបល់ ដែលបានលើកឡើងដោយអ្នកនិពន្ធនៅក្នុងឯកសារនេះមិនបានឆ្លុះបញ្ចាំង ឬបង្ហាញពីគំនិតរបស់ GIZ ឡើយ។ ឯកសារនេះត្រូវបានចងក្រងឡើងជាឯកសារជំនួយ។ តាងនាមឱ្យក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ)។

## គណៈកម្មការរៀបរៀងសៀវភៅ

## គោលការណ៍ណែនាំបច្ចេកទេសស្តីពីការអនុវត្តកសិកម្មល្អម្ទេសដៃនាង

| | |
|---|---|
| ១. ឯកឧត្តម **ងិន ឆាយ** | អគ្គនាយកដ្ឋានកសិកម្ម |
| ២. បណ្ឌិត **គៀន សុភា** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ៣. បណ្ឌិត **សោម លន់** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ៤. លោក **ម៉ៅ តុងហៅ** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ៥. លោក **អន វណ្ណៈ** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ៦. លោកស្រី **ម៉ម ស៊ីថា** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ៧. លោក **ណុប សំណាង** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ៨. លោក **ផន ប្រុស** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ៩. លោកស្រី **ជុំ វណ្ណារិទ្ធ** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ១០. លោកស្រី **ហ៊ាង ចន្ធូ** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ១១. លោកស្រី **ចាន់ សុធី** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ១២. លោក **ហ៊ុន ដារិន** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ១៣. លោក **ចែម សុជា** | នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ១៤. លោក **សូត្រ ធារ៉ា** | រចនាក្រាហ្វិកសៀវភៅ |

# គោលបំណង

- សៀវភៅនេះត្រូវបានចងក្រងឡើងក្នុងគោលបំណង ផ្តល់ជាពត៍ដើម្បីបង្កើនការយល់ដឹងស្តីអំពីគោលការណ៍ណែនាំការដាំដុះដំណាំម្ទេសដៃនាងអនុវត្តតាមកសិកម្មល្អ(GAP)នៅក្នុងការធ្វើផលិតកម្មតែប៉ុណ្ណោះ ។
- គោលបំណងសំខាន់បំផុតនៃសៀវភៅគោលការណ៍ណែនាំការដាំដុះដំណាំម្ទេសដៃនាង អនុវត្តតាមកសិកម្មល្អ(GAP) គឺចង់ធ្វើការផ្សព្វផ្សាយដល់កសិករកម្ពុជាឱ្យបានយល់ដឹងពីការដាំដុះម្ទេសដៃនាងដែលអនុវត្តតាមកសិកម្មល្អ(GAP) កាន់តែមានគុណភាព សុវត្ថិភាពឱ្យបានត្រឹមត្រូវ។
- ដើម្បីបង្កើនចំណេះដឹង និងជាគន្លឹះផ្តល់ដល់កសិករក៏ដូចជាមិត្តអ្នកអានស្តីពីការដាំដុះដំណាំម្ទេសដៃនាងដែលអនុវត្តតាមកសិកម្មល្អ(GAP) ឱ្យកាន់តែទូលំទូលាយនៅកម្ពុជា។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវបច្ចេកទេស និងវិធីសាស្ត្រដាំដុះម្ទេសដៃនាងស្របតាមការអនុវត្តតាមកសិកម្មល្អ(GAP) ។
- ដើម្បីបង្កើនសុវត្ថិភាព និងសុខុមាលភាពដល់ពលរដ្ឋយើង
- ដើម្បីបង្កើនប្រាក់ចំណូលដល់កសិករ

# មាតិកា


សេចក្តីផ្តើម 2

១.បច្ចេកទេសដាំដុះ 3

១.១ ការជ្រើសរើសពូជ 3

១.២ ការរៀបចំដី 3

១.៣. ការធ្វើរានបណ្តុះកូន 5

១.៤. ការរៀបចំដីបណ្តុះកូន 6

១.៥ ការរៀបចំបណ្តុះកូន 6

១.៦. ការដាំកូនម្ទេស 7

២. ការថែទាំ 7

២.១. ការដាក់ជី 7

២.២. ការដោតទំរ និងការតាក់តែងមែក 10

២.៣. ការស្រោចស្រព 11

៣. ការគ្រប់គ្រងជំងឺ និងសត្វល្អិតចង្រៃ 11

៣.១. ជំងឺអង់ត្រាក់ណូស 11

៣.២. ជំងឺបាត់តេរីអុច ឬជំងឺច្រេះ 12

៣.៣. ជំងឺស្រពោន 13

៣.៤. រុយស 13

៤. បច្ចេកទេសមុន និងក្រោយពេលប្រមូលផល 15

ឯកសារយោង 18

# អារម្ភកថា

សៀវភៅគោលការណ៍ណែនាំស្តីពីការដាំដុះដំណាំម្ទេសដៃនាង អនុវត្តតាមកសិកម្មល្អ(GAP) ត្រូវបានរៀបរៀងឡើងដោយនាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំនៃអគ្គនាយកដ្ឋានកសិកម្ម។ សៀវភៅនេះមានគោលបំណងសំខាន់គឺផ្តល់ជូនកសិករ និងអ្នកអាននូវគំនិតដែលជាគន្លឹះសម្រាប់យកទៅអនុវត្តការងារដាំដុះដំណាំម្ទេសដៃនាង ដើម្បីឱ្យទទួលបានផលិតផលល្អ និងគោរពតាមស្តង់ដារសុវត្ថិភាពចំណីអាហារតាមគោលការណ៍អនុវត្តតាមកសិកម្មល្អ(GAP) ។

សៀវភៅនេះបានធ្វើការអត្ថាធិប្បាយចំណុចសំខាន់ៗ ដែលជាគោលការណ៍ណែនាំស្តីពីការដាំដុះដំណាំម្ទេសដៃនាងអនុវត្តតាមកសិកម្មល្អ(GAP)។ យើងជឿជាក់ថាព័ត៌មានទាំងឡាយដែលបានសរសេររៀបរៀងនៅក្នុងសៀវភៅនេះពិតជាមិនទាន់មានន័យគ្រប់គ្រាន់ គឺអាចនៅមានការខ្វះចន្លោះឬក៏ជាក់លាក់ឥតល្អៀងនោះឡើយ យើងខ្ញុំសង្ឃឹមថានាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំនៃអគ្គនាយកដ្ឋានកសិកម្មនឹងខិតខំបំពេញបន្ថែម ឬក៏កែលម្អនៅពេលអនាគតស្របតាមបរិបទបច្ចេកវិទ្យាជឿនលឿនព្រមទាំងទទួលបាននូវព័ត៌មានឬទិន្នន័យផ្សេងៗពីការពិសោធន៍សិក្សាស្រាវជ្រាវបន្ថែមទៀត។

នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំនៃអគ្គនាយកដ្ឋានកសិកម្មសង្ឃឹមថាសៀវភៅនេះនឹង បានចូលរួមជាជំនួយយ៉ាងច្រើនចំពោះកសិករ និងមិត្តអ្នកអានសម្រាប់ជាប្រទីប ឬជាពុទ្ធិផ្ទាល់ខ្លួន និងសម្រាប់អប់រំផ្សព្វផ្សាយបន្ត។ ជាមួយគ្នានេះក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានកសិកម្មដែលបានជំរុញឱ្យមានការបោះពុម្ពនេះឡើង។

សូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសរបស់នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំដែលបានជួយជ្រោមជ្រែងផ្តល់ជាគំនិតយោបល់ និងចំណេះដឹងដើម្បីកើតចេញជាសៀវភៅនេះឡើង។

ខែ វិច្ឆិកា ឆ្នាំ ២០២២

# សេចក្ដីផ្ដើម

ម្ទេស គឺដំណាំមួយប្រភេទដែលត្រូវបានគេទទួលស្គាល់ និងពេញនិយមប្រើប្រាស់ជាយូរលង់ណាស់មកហើយ មិនតែប៉ុណ្ណោះវាត្រូវបានគេដាំដុះនៅពាសពេញពិភពលោក។ លក្ខណៈពិសេសរបស់ម្ទេសគឺមានរសជាតិហឹរ ដែលប្រជាជននៅលើពិភពលោកនិយមបរិភោគជាពិសេសនៅតំបន់អាស៊ី ពេលទុំមានពណ៌ក្រហមក្លិនឆ្ងួល ហើយអាចលូតលាស់យូរឆ្នាំជាងពូកដំណាំក្នុងគ្រួសារដូចគ្នា ។

ម្ទេស គឺជាដំណាំដែលមិនងាយស្រួលនៅក្នុងការដាំដុះប៉ុន្មានទេ វា។ ទាមទារឱ្យអ្នកផលិតមានការយល់ដឹងច្បាស់លាស់អំពីបច្ចេកទេសដូចជា ការរៀបចំដី ការគ្រប់គ្រងទឹក និងការថែទាំផ្សេងៗជាច្រើនទៀត ។

ការអនុវត្តកសិកម្មល្អ (GAP) គឺជាស្តង់ដារស្ម័គ្រចិត្តមួយសម្រាប់ការអនុវត្តការងារកសិកម្មល្អ ក្នុងអំឡុងពេលធ្វើផលិតកម្ម ពេលប្រមូលផល និងក្រោយពេលប្រមូលផលបន្លែ ផ្លែឈើស្រស់ ដើម្បីការពារ និងកាត់បន្ថយគ្រោះថ្នាក់ដែលអាចកើតឡើងឱ្យនៅទាបបំផុត ដើម្បីទទួលបានផលិតផលដែលមានគុណភាព និងផ្តល់នូវសុវត្ថិភាពដល់អ្នកបរិភោគ។

## គោលបំណងរួមនៃការអនុវត្តកសិកម្មល្អ ( GAP )

### ១. សុវត្ថិភាពចំណីអាហារ

ជៀសវាងការប្រើប្រាស់នូវសារធាតុគីមីលើសកម្រិតដោយចេតនា ឬ អចេតនាលើផលិតផលដែលនាំឱ្យប៉ះពាល់ដល់សុខភាពមនុស្ស នៅមុនពេល អំឡុងពេល និងក្រោយពេល ប្រមូលផល។

### ២. គុណភាពផលិតផល

ជ្រើសរើសពូជសុទ្ធ មានប្រភពច្បាស់លាស់ និងការថែទាំ ការផ្តល់សារធាតុចិញ្ចឹមសមស្រប ដើម្បីទទួលបានផលិតផលដែលមានគុណភាព នៅមុនពេល អំឡុងពេល និងក្រោយពេលប្រមូលផល។

### ៣. សុវត្ថិភាព និងសុខុមាលភាពកម្មករ

បង្កលក្ខខណ្ឌសុវត្ថិភាព អនាម័យ ដល់កម្មករ ដើម្បីបង្ការរាល់ហានិភ័យដែលអាចប៉ះពាល់ដល់សុខភាព នៅមុនពេល អំឡុងពេល និងក្រោយពេលប្រមូលផល។

### ៤. ការគ្រប់គ្រងបរិស្ថាន

ជៀសវាងរាល់សកម្មភាពទាំងឡាយណាដែលអាចធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន នៅមុនពេល អំឡុងពេល និងក្រោយពេលប្រមូលផល។

## ១.បច្ចេកទេសដាំដុះ

### ១.១ ការជ្រើសរើសពូជ

កត្តាពូជគឺជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមចំណែកធ្វើឱ្យការដាំដុះបានល្អប្រសើរ អាចទទួលបានទិន្នផលខ្ពស់ ។

ការជ្រើសរើសពូជត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- ពូជសុទ្ធល្អ មានប្រភពច្បាស់លាស់ (ពូជក្នុងស្រុក ឬពូជបង្កាត់)និងផ្តល់ឱ្យទិន្នផលខ្ពស់
- ពូជមានអាយុកាលត្រឹមត្រូវ ឬពូជមិនប្រកាន់រដូវ
- ពូជធន់ទ្រាំទៅនឹងអាកាសធាតុ ជំងឺ សត្វល្អិត និងកត្តាចង្រៃផ្សេងៗ
- ពូជដែលមានលក្ខណៈសមស្របទៅនិងការដាំដុះ
- ពូជមានគុណភាពល្អ និងមានអត្រាដំណុះខ្ពស់លើស ៨៥%
- ត្រូវជ្រើសរើសពូជដែលមានតម្រូវការទីផ្សារខ្ពស់
- ចំពោះពូជដំណាំដែលផលិតដោយខ្លួនឯងត្រូវជ្រើសរើសគ្រាប់ពូជចេញពីដើមមេបាដែលមានប្រភពច្បាស់លាស់ និងត្រូវកត់ត្រាពីប្រភព កាលបរិច្ឆេទនៃការផលិតពូជ
- ត្រូវទិញកូនដំណាំដែលផលិតស្របតាមបច្ចេកទេស និងមានការទទួលស្គាល់ពីស្ថាប័នកសិកម្ម និងត្រូវកត់ត្រាឈ្មោះ អាសយដ្ឋានអ្នកផ្គត់ផ្គង់ និងកាលបរិច្ឆេទនៃការផ្គត់ផ្គង់
- ទីកន្លែង និងសម្ភារៈនៃការផលិតពូជត្រូវតែស្អាតមិនមានភាពកខ្វក់ឡើយ



ពូជមានគុណភាពល្អ

### ១.២ ការរៀបចំដី

ត្រូវដឹងពីប្រវត្តិនៃការដាំដុះពីមុន ជំរាលដី ដីមានជីជាតិ និងមានប្រភពទឹកស្រោចស្រពល្អ។ ត្រូវវាយតម្លៃប្រភពដែលអាចចម្លងសារធាតុគីមីជីវសាស្ត្រ ប្រវត្តិនៃការប្រើប្រាស់កសិដ្ឋានពីមុន និងការប្រើប្រាស់បច្ចុប្បន្ន និងសកម្មភាពនានានៃដី ឬកសិដ្ឋានដែលនៅក្បែរ។ ប្រភពនៃការចម្លងមានដូចជា កន្លែងជីកយករ៉ែ គំនសំរាម រោងចក្រ សិប្បកម្ម កសិដ្ឋានចិញ្ចឹមសត្វ។ កន្លែងមានហានិភ័យសំខាន់ៗទាំងនោះត្រូវចាត់វិធានការ និងកត់ត្រារាល់សកម្មភាពហានិភ័យនោះ

### ក. ការភ្ជួររាស់

- ត្រូវសំអាតដីចំការ និងរើសស្មៅចេញឱ្យអស់មុនពេលភ្ជួរដី (គោ ឬគោយន្ត) ភ្ជួរដីឱ្យបាន ២ ទៅ ៣ ដងក្នុងជម្រៅពី ២០ ទៅ ៣០ស.ម
- ត្រូវភ្ជួររាស់បំបែកដីឱ្យបានម៉ដល្អ រួចហាល ឱ្យបានពី ១០ ទៅ ១៥ថ្ងៃ ។



ភ្ជួរដីជម្រៅ២៥ - ៣០សម



ហាលថ្ងៃរយៈពេលពី ៧-១០ ថ្ងៃ

### ខ. ការរៀបចំលើករង

- ការលើករង
  - ទទឹងរងៈ ១ម៉ែត្រ និងបណ្ដោយទៅតាមលទ្ធភាពដី ប៉ុន្តែមិនឲ្យលើសពី ១៥ម៉ែត្រ ជាហេតុធ្វើឱ្យពិបាកក្នុងការថែទាំដូចជាស្រោចទឹក ដកស្មៅជាដើម
  - កំពស់រងៈ នៅរដូវប្រាំងពី ២០-៣០សង់ទីម៉ែត្រ និងរដូវវស្សាពី ៣០-៥០សង់ទីម៉ែត្រ
  - ដាក់ជីលាមកសត្វស្ងួត ឬជីកំប៉ុស្ដ៍ ក្នុងបរិមាណ ២-៣គីឡូក្រាម ក្នុងផ្ទៃដី១ម៉ែត្រការ៉េ និងដាក់ជីគីមី អិន-ប៉េ-កា (២០-២០-១៥ , ១៥-១៥-១៥) លាយច្របល់ជាមួយដី
  - ការគ្របរងដាំៈ អាចទប់ស្កាត់ការហូរច្រោះរង ការពារសំណើមដី និងកាត់បន្ថយការដុះស្មៅ

➢ **ធ្វើរងប្រើប្លាស្ទិចគ្របដី**





លើករងកម្ពស់ ៣០សម



១.កាធ្វើបន្ទះឬស្សីសម្រាប់ខ្ទាស់



២.ដោតកន្លាសឬស្សីនៅជារង
នឹងខាងចុងរង



៣.លាតសន្ទឹងដុំប្លាស្ទីច



៤.ដោតកន្លាសឬស្សីនៅសង់



៥.យកដីសង្កត់ជើងរងសងខាង



៦.ចោះរណ្ដៅដាំកូនខាងរងប្រវែង
ដោយប្រើកំប៉ុងពី១៥-២០ស.ម

**ចំណាំ:**

- ប្រើប្រាស់វត្ថុធាតុដើមទាំងឡាយណាដែលអាចរកបានដូចជា ឫស្សី ឬធាងត្នោត។ គ្របប្លាស្ទិចឱ្យតឹងល្អរាបស្មើជាប់នឹងផ្ទៃរងដី (ប៉ុន្តែកុំឱ្យតឹងខ្លាំងអាចរហែកប្លាស្ទិច) ជៀសវាងកុំឱ្យមានប្រហោះខ្យល់នៅខាងក្នុងអាចបង្កឱ្យរលាកកូនដំណាំ
- ក្នុងករណីដីមានគ្រួសធំៗនៅតាមរង ជាហេតុបណ្ដាលឱ្យប្លាស្ទិចរហែកយើងអាចយកចំបើង ឬអង្កាមគ្របពីលើប្លាស្ទិក។

### ១.៣. ការធ្វើរានបណ្ដុះកូន




- ដំបូលសម្រាប់គ្របរានៈ កំពស់ ១,៨ ទៅ ២ម៉ែត្រ ដើម្បីងាយស្រួលចេញចូលថែទាំ
- កំពស់រានៈ ០,៥-០,៧ម៉ែត្រពីដី
- ទទឹងរានៈ ០,៨-១ម៉ែត្រ
- ធ្វើដំបូលការពារទឹកភ្លៀង និងសំណាញ់ការពារពន្លឺថ្ងៃ (គប្បីសំណាញ់ពណ៌បៃតង)
- ធ្វើសំណាញ់ព័ទ្ធជុំវិញដើម្បីការពារសត្វល្អិត។

ធ្វើបែបនេះ ៖ កាត់បន្ថយការរលួយកូន គ្រាប់ដុះបានល្អ និងការពារបានពីការឆ្លងជំងឺពីសត្វល្អិតចង្រៃ។

### ១.៤. ការរៀបចំដីបណ្ដុះកូន

- យកដីមានជីជាតិ ១ភាគលាយជាមួយជីលាមកគោស្ងួត ឬជីកំប៉ុស្ដ៍ ២ភាគ និងផេះអង្កាម ២-៣ភាគ (ផេះអង្កាមត្រូវត្រាំទឹករយៈពេល ៣-៤យប់)
- យកល្បាយដីបានលាយច្របល់ហើយលីងរហូតក្ដៅសព្វទាំងអស់ផលប្រយោជន៍នៃការលាយដីគឺ៖
  - គ្រាប់បន្លែងាយដុះ ឬសដុះលូតលាស់ល្អ
  - កូនបន្លែស្រូបយកជីជាតិបានគ្រប់គ្រាន់
  - សម្លាប់គ្រាប់ស្មៅចង្រៃដែលដុះដណ្ដើមជីជាតិពីកូនបន្លែ
  - សម្លាប់មេរោគ ពងដង្កូវ និងសត្វល្អិតចង្រៃដែលមាននៅក្នុងល្បាយដី ដែលបង្កឱ្យកូនបន្លែរលួយ។




### ១.៥ ការរៀបចំបណ្ដុះកូន

- ត្រូវរៀបចំបណ្ដុះកូនបន្លែ ស្របពេលជាមួយគ្នានឹងការរៀបចំដី
- ការបណ្ដុះកូនបន្លែមានពីររបៀប៖

**ក. បណ្ដុះគ្រាប់មុន**



- យកគ្រាប់ដាក់ពង្រាយក្នុងក្រណាត់ស្បៃជក់ទឹកបន្ទាប់មករុំគ្រាប់ឱ្យហប់ល្អ
- ស្រោចទឹករៀងរាល់ថ្ងៃដើម្បីឱ្យក្រណាត់ស្បៃសើម ហើយដាក់ទីកន្លែងហប់មានកំដៅ
- ផ្អាប់គ្រាប់រយៈពេល ១-២យប់
- ជ្រើសរើសយកគ្រាប់បែកមាត់ដាក់១គ្រាប់ ក្នុងកន្ទោង ឬ១រន្ធថាសបណ្ដុះ
- ដាក់គ្រាប់ជំរៅ ១ស.ម ប្រសិនបើដាក់គ្រាប់ជ្រៅពេក ឬរាក់ពេក វាធ្វើឲ្យគ្រាប់មិនដុះ
- រោយដីស្ដើងៗគ្របពីលើ បន្ទាប់មកស្រោចទឹកឱ្យជោគរៀងរាល់ពេលព្រឹក (១-២ដងក្នុង១ថ្ងៃអាស្រ័យតាមស្ថានភាពដី) ប្រសិនបើដីស្ងួតពេក អាចធ្វើឱ្យគ្រាប់មិនដុះ។

### ខ. ការបណ្តុះកូនក្នុងថាសបណ្តុះ ឬ កន្ទោង

- យកគ្រាប់ស្ងួតចំនួន១គ្រាប់ដាក់បណ្តុះផ្ទាល់ ក្នុង១កន្ទោង ឬ ១រន្ធថាសបណ្តុះ។
- ដាក់គ្រាប់ជំរៅ ១ស.ម ប្រសិនបើដាក់គ្រាប់ជ្រៅពេក ឬរាក់ពេក អាចធ្វើឱ្យគ្រាប់មិនដុះ
- រោយដីស្តើងៗគ្របពីលើ បន្ទាប់មកស្រោចទឹកឱ្យជោគរៀងរាល់ពេលព្រឹក (១-២ដងក្នុង១ថ្ងៃអាស្រ័យតាមស្ថានភាពដី) ប្រសិនបើដីស្ងួតពេក អាចធ្វើឱ្យគ្រាប់មិនដុះ។
- យកថាស ឬកន្ទោងដែលបានដាក់គ្រាប់ហើយ ទៅដាក់លើរាន ដែលមានសំណាញ់សត្វល្អិតការពារ។



### ១.៦. ការដាំកូនម្ទេស

- បន្ទាប់ពីកូនម្ទេសដុះបានអាយុ ២២-២៥ថ្ងៃ (កូនម្ទេសដុះស្លឹក ៤-៥សន្លឹក) អាចយកទៅដាំបាន
- ត្រូវយកកូនម្ទេសដាក់ឲ្យត្រូវពន្លឺថ្ងៃរយៈពេលពី ៣-៥ ថ្ងៃ និងកាត់បន្ថយការស្រោចទឹកដើម្បីឲ្យកូនម្ទេសមានសុខភាពល្អមុននឹងយកកូនទៅដាំក្នុងចំការ។
- បញ្ចូលទឹកតាមចន្លោះរងនៅពេលព្រឹក (ប្រសើរបំផុតសម្រាប់រងដាំដោយគ្របប្លាស្ទិចប៉ុណ្ណោះ)
- ដកកូនម្ទេសថ្នមៗចេញពីថាសបណ្តុះដោយយកដៃម្ខាងរុញបាទថាសឡើងលើដៃម្ខាងទាញគល់កូនម្ទេសដកចេញពីថាស។
- ដាក់ថ្នាំពុលកសិកម្ម ដាយណូតីហ្វូយរ៉ាន់ (Dinotefuran) មុនពេលដាំ ២គ្រាម/រណ្តៅ។ យើងអាចដាក់មុន ឬ ក្រោយពេលដាំ (យ៉ាងយូរ៧ថ្ងៃបន្ទាប់ពីដាំ) ដើម្បីការពារសត្វល្អិតចង្រៃបំផ្លាញដំណាំដូចជាពពួកសត្វល្អិតជញ្ជក់ (រុយស ចៃ ទ្រីប...)
- ដាំកូនម្ទេសដាក់ត្រឹមដីកំណើត (ដីបណ្តុះ)

## ២. ការថែទាំ

### ២.១. ការដាក់ជី

#### ក. ទីតាំងដាក់ជីបំប៉ន

- រងគ្របប្លាស្ទិច ឬ គ្របចំបើង ត្រូវយកឈើបុករណ្តៅសងខាងគុម្ព ទើបដាក់ជី

- រយៈពេល២សប្តាហ៍បន្ទាប់ពីដាំកូនត្រូវដាក់ជីចំងាយ ៥ស.ម ពីគល់
- រយៈពេល៤សប្តាហ៍បន្ទាប់ពីដាំកូនត្រូវដាក់ជីចំងាយ ១០ស.ម ពីគល់
- ប្រសិនបើលើសពី៦សប្តាហ៍ ត្រូវដាក់ជីនៅចន្លោះកណ្តាលពីគុម្ពមួយទៅគុម្ពមួយ។

**ខ. ពេលវេលាដាក់ជីបំប៉ន**

- ត្រូវដាក់ជីបំប៉នឱ្យបានទៀងទាត់ចន្លោះពេលពី ៧-១៥ថ្ងៃ ម្តងបន្ទាប់ពីដាំកូនបន្លែ គឺអាស្រ័យតាមប្រភេទដី។ ចំពោះដីខ្សាច់ត្រូវដាក់ជីឱ្យបានញឹកញាប់ក្នុងបរិមាណតិចជាងដីមានល្បាយច្រើនជាងខ្សាច់។
- មិនត្រូវដាក់ជីនៅពេលថ្ងៃក្តៅដើម្បីជៀសវាងកាប៉ះពន្លឺថ្ងៃក្តៅខ្លាំងធ្វើឱ្យជីភាយហើយឆួលខ្លោចស្លឹកដើម
- ស្រោចទឹកភ្លាមបន្ទាប់ពីដាក់ជីរួច(ជៀសវាងដាក់ជីគីមីនៅពេលថ្ងៃក្តៅ វាបង្កឱ្យឆួលខ្លោចដំណាំ)

**គ. បរិមាណជីដែលត្រូវប្រើ**

| ចំនួនថ្ងៃបន្ទាប់ពីដាំ | ប្រភេទជី | បរិមាណជី | កន្លែងដាក់ជី |
|---|---|---|---|
| មុនដាំ ៥ថ្ងៃ ឬពេលដាំ | ជីអិន ប៉េ កា (២០-២០-១៥,១៥-១៥-១៥) | ១០ក្រាម/ដើម | ទ្រាប់បាត |
| | ជីសរីរាង្គ | ២គីឡូក្រាម/ដើម | ទ្រាប់បាត |
| ៩ | ជីអិន ប៉េ កា (២០-២០-១៥,១៥-១៥-១៥) | ៥ក្រាម/ដើម | បំប៉ន |
| | ជីអាសូត (៤៦-០-០) | ៥ក្រាម/ដើម | បំប៉ន |
| ២៣ | ជីអិន ប៉េ កា (២០-២០-១៥,១៥-១៥-១៥) | ៥ក្រាម/ដើម | បំប៉ន |
| | ជីអាសូត (៤៦-០-០) | ៥ក្រាម/ដើម | បំប៉ន |
| ៣៧ | ជី អិនប៉េ (១៦-២០-០)ឬជីអិនប៉េ កា(២០-២០-១២) | ៥ក្រាម/ដើម | បំប៉ន |
| | ជី ប៉ូតាស្យូម (០-០-៦០) | ១០ក្រាម/ដើម | បំប៉ន |
| ៥១ | ជីអិន ប៉េ កា (២០-២០-១៥,១៥-១៥-១៥) | ៥ក្រាម/ដើម | បំប៉ន |
| ៦៥ | ជី អិនប៉េ (១៦-២០-០)ឬជីអិនប៉េ កា(២០-២០-១២) | ៥ក្រាម/ដើម | បំប៉ន |
| | ជី ប៉ូតាស្យូម (០-០-៦០) | ១០ក្រាម/ដើម | បំប៉ន |
| ៧៩ | ជីអិន ប៉េ កា (២០-២០-១៥,១៥-១៥-១៥) | ៥ក្រាម/ដើម | បំប៉ន |
| ៨៦ | ជី ប៉ូតាស្យូម (០-០-៦០) | ៥ក្រាម/ដើម | បំប៉ន |
| ៩៣ | ជីអិន ប៉េ កា (២០-២០-១៥,១៥-១៥-១៥) | ៥ក្រាម/ដើម | បំប៉ន |
| ១០៣ | ជីអិន ប៉េ កា (២០-២០-១៥,១៥-១៥-១៥) | ៥ក្រាម/ដើម | បំប៉ន |

- បាញ់ជីបំប៉នស្លឹក បន្ទាប់ពីដាំកូនម្ទេសអាយុបាន៧ថ្ងៃ រហូតដល់ពេលចាប់ផ្តើមចេញផ្កាដំបូង រៀងរាល់៧ថ្ងៃម្តង
- បាញ់ជីបំប៉នផ្កាផ្លែ បន្ទាប់ពីម្ទេសចាប់ផ្តើមចេញផ្កាដំបូង រៀងរាល់៧ថ្ងៃម្តង

- ត្រូវដាក់ពីចំងាយ ពី ៥ ទៅ ១៥ ស.ម ពីគល់ម្ទេស។ លប់ដីពីលើ បន្ទាប់ពីដាក់ជីរួច
- ជី១០ក្រាម (ប្រហែល ១ស្លាបព្រាបាយស្មើ) និងជី៥ក្រាម (ប្រហែល កន្លះស្លាបព្រាបាយ)
- បរិមាណជីដែលដាក់ខាងលើនេះអាស្រ័យទៅតាមស្ថានភាពលូតលាស់ដំណាំម្ទេស។

**ចំណាំ:**

- ទីកន្លែងធ្វើជី និងថ្នាំពុលធម្មជាតិត្រូវស្ថិតនៅឆ្ងាយពីទីកន្លែងដាំដុះ និងប្រភពទឹក
- ជីកំប៉ុស្តត្រូវតែពុកផុយល្អ គ្មានកំដៅ និងអាយុលើសពី ៣ ទៅ ៤ខែ ឡើងទៅ
- ការផលិតជីកំប៉ុស្តត្រូវសាងសង់រោងសម្រាប់ស្តុកទុកជីកំប៉ុស្ត
- ត្រូវកត់ត្រាឱ្យបានច្បាស់លាស់ ពីថ្ងៃ ខែ ឆ្នាំដាក់ជី ឈ្មោះផលិតផល អ្នកប្រើប្រាស់ ប្រភព កន្លែងប្រើប្រាស់ និងបរិមាណប្រើប្រាស់





ប្រក់ស្លឹករបាំងឫស្សី



ប្រក់ស្លឹករបាំងបិតដី



ប្រក់តង់របាំងបេតុង



ប្រក់ស្លឹករបាំងបេតុង




## ២.២. ការដោតទំរ និងការកាត់តែងមែក

- ត្រូវដោតទ្រើងឱ្យរួចរាល់បន្ទាប់ពីដាំកូនម្ទេសរួចរាល់រយៈពេល២សប្តាហ៍
- ការដោតទ្រើងតាមរបៀបផ្សេងៗគ្នា ដែលអាចធ្វើបាន ដើម្បីទប់ដើម មែក ធ្លាក់មកលើដី
- កាត់ខ្នែងផ្នែកខាងក្រោម ដើម្បីឱ្យមានខ្យល់ និងពន្លឺចេញចូលគ្រប់គ្រាន់







### ២.៣. ការស្រោចស្រព

- បន្ទាប់ពីដាំកូននៅលើរងរយៈពេល២សប្តាហ៍ ត្រូវស្រោចទឹកកូនម្ទេសរៀងរាល់ថ្ងៃដើម្បីឱ្យឫសរបស់វារឹងមាំ និងលូតលាស់បានល្អ។
- កុំទុកដីឱ្យស្ងួតរយៈពេលយូរថ្ងៃជាប់ៗគ្នារហូតដល់៣ថ្ងៃ ជាពិសេសក្នុងពេលម្ទេសចេញផ្កា និងផ្លែ
- ស្រោចទឹកតាមចន្លោះរង
- ត្រូវប្រើប្រាស់ទឹកស្អាត (គ្មានសារធាតុពុលគីមី និងមេរោគ) ក្នុងការស្រោចស្រពដំណាំ ការលាយដីបាញ់ថ្នាំ និងការលាងសម្អាត
- ត្រូវវិភាគទឹកយ៉ាងហោចណាស់ឱ្យបានមួយឆ្នាំម្តង
- ត្រូវស្រោចស្រពឱ្យស្របតាមដំណាក់កាលលូតលាស់របស់ដំណាំម្ទេស ក្នុងករណីមានលទ្ធភាពអាចប្រើប្រព័ន្ធតំណក់ទឹកកាន់តែល្អ
- ការពារប្រភពទឹកកុំឱ្យមានកាកសំណល់សត្វ សំរាម ឬសារធាតុកខ្វក់ផ្សេងៗហូរចូលក្នុងប្រភពទឹក។

## ៣. ការគ្រប់គ្រងជំងឺ និងសត្វល្អិតចង្រៃ

### ៣.១. ជំងឺអង់ត្រាក់ណូស

ជំងឺនេះច្រើនកើតមាននៅពេលចាប់ផ្តើមប្រមូលផ្លែម្ទេស វាកើតមាននៅលើផ្លែទុំ ឬ ផ្លែខ្ចី។ ជំងឺអង់ត្រាក់ណូសកើតមានដោយសារប្រើគ្រាប់មានជាប់ជំងឺនេះ ឬ ឆ្លងពីកាកសំណល់ដំណាំដែលមានជំងឺនេះក្នុងចម្ការ។ ការស្រោចទឹកភ្លៀង និងទឹកសន្សើមដែលធ្លាក់ពីដើមមានជំងឺគឺជាលក្ខខណ្ឌសមស្របសម្រាប់ជំងឺរីករាលដាលលឿនទៅដើមដទៃទៀតនៅក្នុងចំការ។

**វិធីការពារ**

- ជ្រើសរើសគ្រាប់ពូជមានគុណភាពល្អ គ្មានជំងឺ និងសត្វល្អិតបំផ្លាញ
- ដាំដំណាំឆ្លាស់
- ប្រមូលដើមដែលមានជំងឺយកទៅកប់ ឬដុតចោល
- បាញ់ថ្នាំផ្សិតរវាង ៧-១០ថ្ងៃម្តងពីខាងក្រោមស្លឹក និងខាងលើស្លឹកនៅពេលល្ងាច។ យើងអាចជ្រើសរើសយកថ្នាំផ្សិត ខាងក្រោមដែលមាននៅលើទីផ្សារបាញ់ឆ្លាស់គ្នា។ ថ្នាំពុលកសិកម្មសម្រាប់កំចាត់ជំងឺពពួកផ្សិតដូចជាៈ
    - ម៉ង់កូហ្សេប លាយជាមួយមេតាឡាក់ស៊ីល (Mancozeb + Metalaxyl) ឬ
    - អាហ្សូហ្ស៊ីនស្រូប៊ីន (Azoxystrobin) ឬ ក្លរ៉ូថាឡូនីល (Chlorothalonil) ឬ កាប់តែនCaptan) ឬ
    - ផ្សិតជីវសាស្ត្រទ្រីកូឌែម៉ា




### ៣.២. ជំងឺបាត់តេរីអុច ឬជំងឺច្រេះ

ជំងឺនេះ កើតមាននៅលើស្លឹក ទងស្លឹក ផ្លែ និងដើម។ ជំងឺនេះបណ្តាលមកពី ប្រើគ្រាប់ពូជមានមេរោគ ឆ្លងកាកសំណល់បន្លែ មានជំងឺក្នុងចម្ការ ស្រោចទឹកពីលើផ្លែប៉ះស្លឹក ដើម មានសន្សើម និងភ្លៀងធ្លាក់ច្រើន និងសីតុណ្ហភាពខ្ពស់។

**វិធីការពារ**

- ដាំពូជម្ទេសមានគុណភាពល្អ គ្មានជំងឺនេះ និងជ្រើសរើសយកតែកូនម្ទេសដែលគ្មានជំងឺនេះទៅដាំ និងប្រមូលផ្លែ ស្លឹក ដើមមានជំងឺទៅកប់ឬដុតចោល
- បាញ់ថ្នាំផ្សិតរវាង ៧-១០ថ្ងៃម្តងពីខាងក្រោមស្លឹក និងខាងលើស្លឹកនៅពេលល្ងាច។ យើងអាចជ្រើសរើសយកថ្នាំផ្សិត ខាងក្រោមទៅបាញ់ឆ្លាស់គ្នា។ ថ្នាំពុលកសិកម្មសម្រាប់កម្ចាត់ជំងឺពពួកផ្សិតដូចជាៈ

- ម៉ងកូហ្សែប លាយជាមួយមេតាឡាក់ស៊ីល (Mancozeb + Metalaxyl) ឬបាញ់ថ្នាំផ្សិតកូភើ (Copper) ឬផ្សិតជីវសាស្ត្រទ្រីកូឌែម៉ា




### ៣.៣. ជំងឺស្រពោន

ជំងឺនេះចាប់ផ្តើមស្រពោនស្លឹកនៅផ្នែកខាងក្រោម (ចំពោះកូនម្ទេសវិញគឺស្រពោនពីស្លឹកនៅផ្នែកខាងលើ) បន្ទាប់មកដើមម្ទេសចាប់ផ្តើមស្រពោនទាំងអស់។ បាក់តេរីបង្ករជំងឺនេះរស់នៅក្នុងដីបាន រយៈពេលយូរ។ ប្រសិនបើសំណើមបរិយាយកាសខ្ពស់ និងដើមម្ទេសមានសំណើមខ្ពស់ គឺជំងឺនេះនឹងរីករាលដាលបាយ៉ាងឆាប់រហ័ស។

**វិធីការពារ**

- ជ្រើសរើសដីបណ្តុះដែលគ្មានជំងឺ
- ជ្រើសរើសពូជធន់ទ្រាំទៅនឹងអាកាសធាតុ ជំងឺ សត្វល្អិត និងកត្តាចង្រៃផ្សេងៗ
- ដាំដំណាំឆ្លាស់ (ដាំដំណាំមិនមែនគ្រួសារ/អំបូរជាមួយម្ទេស)
- ដាំកូនម្ទេសដែលមានឫសល្អ
- ប្រមូលដំណាំដែលកើតជំងឺកប់ ឬ ដុតចោល
- រងដំណាំដែលកើតជំងឺស្រពោន មិនត្រូវបង្ហូរទឹកចេញទៅរងផ្សេងទៀតទេពីព្រោះវាអាចឆ្លងជំងឺពេញចំការទាំងមូលបានយ៉ាងឆាប់រហ័សបំផុត។




### ៣.៤. រុយស

រុយសវាបំផ្លាញធ្ងន់ធ្ងរអាចធ្វើឱ្យដំណាំលូតលាស់ខ្សោយ តាមរយៈជញ្ជក់រុក្ខរសពីដើម ។ វាធ្វើឱ្យស្លឹកឡើងពណ៌លឿង និងដើមបាត់បង់កម្លាំងលូតលាស់។ ទឹកដមរុក្ខជាតិ (honeydew) ត្រូវបានផលិតចេញមក ជម្រុញឱ្យមានការដុះផ្សិតពណ៌ខ្មៅ ដែលកាន់តែកាត់បន្ថយកម្លាំងលូតលាស់របស់ដើម ។


មេពេញវ័យ *Bemisia tabaci*


ពង *Bemisia*


ដុកឡឿ និងមេពេញវ័យ *Bemisia*

**វិធីការពារ និងកំចាត់**

- ប្រើអន្ទាក់ពណ៌លឿង និងប្រើប្លាស្ទិចគ្របដីដើម្បីកាត់បន្ថយចំនួនពពួករុយស
- ប្រើថ្នាំពុលកសិកម្ម ដោយណូតីហ្វុយរ៉ាន (Dinotefuran) មុនពេលដាំ ២ក្រាម/រណ្តៅ។ យើងអាចដាក់មុន ឬ ក្រោយពេលដាំ (យ៉ាងយូរ៧ថ្ងៃបន្ទាប់ពីដាំ) ដើម្បីការពារសត្វល្អិតចង្រៃបំផ្លាញដំណាំ ដូចជាពពួកសត្វល្អិតជញ្ជក់រុយស និងសត្វល្អិតជញ្ជក់ផ្សេងៗទៀត
- បាញ់ថ្នាំពុលកសិកម្មដូចជាៈ អ៊ីមីដាក្លូព្រីដ (Imidacloprid) ឌីយ៉ាស៊ីណុល (Diazinon) អាបាមិចទីន (Abamectin)

**សំគាល់៖** មិនត្រូវយកថ្នាំពុលកសិកម្មលាយបញ្ចូលចូលគ្នាច្រើនមុខ សម្រាប់បាញ់ទេព្រោះថ្នាំអាចមានប្រតិកម្មជាមួយគ្នាបណ្តាលឱ្យគ្មានប្រសិទ្ធភាព។

- ត្រូវជ្រើសរើសយកក្បាលបាញ់ទុយោមានលក្ខណៈសាចល្អ ទើបថ្នាំនៅជាប់នឹងដើម និងស្លឹកបន្លែ
- ត្រូវប្រើទឹកស្អាតលាយជាមួយថ្នាំ
- ត្រូវបាញ់នៅខាងលើ និងខាងក្រោមផ្ទៃស្លឹក តាមត្រួយស្លឹក និងដើមឱ្យសព្វល្អ
- ត្រូវបាញ់ថ្នាំពុលកសិកម្មនៅពេលល្ងាច

<u>**ចំណាំ**</u>

- ត្រូប្រើប្រាស់ថ្នាំកសិកម្មដែលបានចុះបញ្ជីកា និងប្រើប្រាស់ទៅតាមការណែនាំលើសំបកដប ឬ កញ្ចប់ថ្នាំ
- ពេលបាញ់ថ្នាំត្រូវពាក់វ៉ែនតាការពារភ្នែក មួក ស្រោមដៃ ម៉ាស ស្បែកជើងកវែង និងអាវការពារ
- ក្រោយពេលបាញ់ថ្នាំរួចត្រូវលាងសម្អាត និងទុកសម្ភារៈឱ្យបានត្រឹមត្រូវ
- ត្រូវទុកដាក់ថ្នាំកសិកម្មឱ្យបានត្រឹមត្រូវនៅទីកន្លែងមានសុវត្ថិភាពល្អ និងមានខ្យល់ចេញចូលល្អ
- ថ្នាំកសិកម្មត្រូវដាក់ឱ្យដាច់ដោយឡែកពីគ្រាប់ពូជ ជី ចំណីសត្វ និងដំណាំដែលប្រមូលផលរួច និងត្រូវមានសញ្ញាសម្គាល់ត្រឹមត្រូវ។









ថ្ងៃខែឆ្នាំ៖..................
ឈ្មោះផលិតផល៖..................
អ្នកប្រើប្រាស់៖........................
ប្រភព៖.......................
ប្រភេទធ្វើប្រព្រឹត្តិកម្ម៖............
កន្លែងប្រើប្រាស់៖..........................
បរិមាណប្រើប្រាស់៖......................







## ៤. បច្ចេកទេសមុន និងក្រោយពេលប្រមូលផល

- ផ្លែអាចបេះទៅតាមតម្រូវការទីផ្សារ
- បេះផ្លែនៅពេលព្រឹក
- សម្ភារៈដាក់ផ្លែត្រូវមានផ្ទៃរលោង
- ជ្រើសរើសម្ទេសដែលល្អដាច់គេ ដោយឡែកពីផ្លែម្ទេសដែលមានជំងឺ ឬ សត្វល្អិតបំផ្លាញ។

**ការគ្រប់គ្រងគុណភាពនៅដំណាក់កាលមុនប្រមូលផល៖**

- ត្រូវធ្វើរោងឱ្យកម្មករសម្រាក និងស្នាក់នៅ ត្រូវមានបន្ទប់ស្អាត និងគ្រប់គ្រាន់
- ទឹក និងប្រព័ន្ធស្រោចស្រពត្រូវតែស្អាត និងថែរក្សាឱ្យបានល្អ ដើម្បីផ្តល់ប្រសិទ្ធិភាពដល់ដំណាំ
- សម្ភារៈទាំងអស់ដែលពាក់ព័ន្ធនឹងការដាំដុះ ការស្តុកទុក ប្រមូលផលដំណាំត្រូវតែស្អាតជាប្រចាំ និងមានកន្លែងរក្សាទុកបានយ៉ាងល្អ
- គួរដាំដំណាំជុំវិញចំការជារបាំងការពារថ្នាំពុល
- ហាមចោលកាកសំណល់កសិកម្មក្បែរប្រភពទឹកស្រោចស្រព

- កាកសំណល់ត្រូវបែងចែកជាពីរប្រភេទ រួមមានកាកសំណល់ប្លាស្ទិក និងកាកសំណល់សរីរាង្គ និងត្រូវមានកន្លែងស្តុកទុកឱ្យបានល្អសម្រាប់កាកសំណល់ប្លាស្ទិក
- សត្វចិញ្ចឹមនៅចំការត្រូវធ្វើទ្រុងឱ្យបានត្រឹមត្រូវ ហាមប្រលែងពាសវាលពាសកាល
- ត្រូវថែរក្សាអនាម័យបន្ទប់ទឹកសម្រាប់កម្មករ បន្ទប់ទឹកមិនគួរនៅជិតប្រភពទឹកស្រោចស្រពឡើយ
- សម្ភារៈលាងសម្អាតដៃ ត្រូវរៀបចំឱ្យមានជាប្រចាំ

**គ្រប់គ្រងគុណភាពនៅដំណាក់កាលប្រមូលផល៖**

- អ្នកប្រមូលផលត្រូវលាងដៃឱ្យស្អាត កាត់ក្រចកដៃឱ្យខ្លី ត្រូវចងសក់ ហាមជក់បារី និងហាមបរិភោគភេសជ្ជៈក្នុងអំឡុងពេលប្រមូលផលម្ទេស
- សម្ភារៈប្រមូលផលត្រូវមានភាពរឹងមាំ និងត្រូវលាងសម្អាតជាប្រចាំមុន និងក្រោយពេលប្រើប្រាស់រួច
- ត្រូវប្រមូលផលដោយប្រុងប្រយ័ត្នជៀសវាងការប៉ះទង្គិចនាំឱ្យមានស្នាមជាំ ឬខូចផ្លែម្ទេស
- មិនត្រូវប្រើប្រាស់កញ្ច្រែង កញ្ចេរដែលដាក់ជីគីមី និងថ្នាំកសិកម្ម ឬសារធាតុគីមីពុលផ្សេងៗ
- ផ្លែម្ទេសដែលបានប្រមូលផលរួចត្រូវដាក់នៅក្នុងម្លប់ និងដាក់ឱ្យឆ្ងាយពីសត្វ កន្លែងដាក់ថ្នាំកសិកម្ម និងកន្លែងដាក់ថ្នាំកសិកម្ម និងកន្លែងដាក់ជីគីមី
- ផ្លែម្ទេសដែលប្រមូលរួចត្រូវដាក់ក្នុងកញ្ច្រែង កញ្ចេរដែលស្អាតមិនត្រូវដាក់ផ្ទាល់ដីឡើយ
- រថយន្តដែលដឹកផលិតផលត្រូវស្អាត និងមានអនាម័យល្អតាមលក្ខណៈបច្ចេកទេស
- ក្នុងពេលដឹកជញ្ជូនមិនត្រូវដាក់ផលិតផលឱ្យប៉ះកំដៅថ្ងៃ ភ្លៀង និងធូលីឡើយ
- មិនត្រូវដឹកផលិតផលលាយឡំជាមួយសត្វពាហនៈ ជីគីមី ឬថ្នាំកសិកម្មផ្សេងៗ
- ការលើកដាក់កសិផលត្រូវប្រុងប្រយ័ត្ន និងរក្សាអនាម័យជានិច្ច
- ត្រូវកត់ត្រាតាមប្រភេទ បរិមាណនៃផលិតផល កាលបរិច្ឆេទ ឈ្មោះកម្មករ ឬសមាជិកគ្រួសារ និងដាក់ឈ្មោះអ្នកបើកបររថយន្តផងដែរ
- មិនត្រូវដាក់ផលិតផលដោយផ្ទាល់ទៅនឹងកន្លែងវេចខ្ចប់ ឬប្រឡាក់ដីឡើយ ដើម្បីជៀសវាងការឆ្លងមេរោគ
- អ្នកបែងចែក ឬវេចខ្ចប់ត្រូវលាងដៃនឹងសាប៊ូ មុនពេលប៉ះពាល់ផលិតផល
- បន្ទប់វេចខ្ចប់ត្រូវតែស្អាត មានខ្យល់ចេញចូលល្អ និងមិនត្រូវមានក្លិនមិនល្អឡើយ
- សម្ភារៈវេចខ្ចប់នីមួយៗត្រូវបិតស្លាកសញ្ញាព័ត៌មានដូចជាកូដអ្នកដាំដុះ ឈ្មោះផលិតផល ទម្ងន់សរុប លេខឡូត៍ និងកាលបរិច្ឆេទវេចខ្ចប់។

| ដំណាំ/ពូជ | ប្លុក | ថ្ងៃខែប្រមូលផល | លេខកូដ | ចំនួនវេចខ្ចប់ | ទិសដៅ | កំណត់សម្គាល់ |
|---|---|---|---|---|---|---|
| ត្រសក់ | C | 12/7/18 | C09182306 | 40Kg | ផ្សារAEON-C092306 | បេះលើទី1 |
| ប៉េងប៉ោះ | A | 14/7/17 | A15174002 | 20Kg | ផ្សារLucky-A154002 | បេះលើកទី2 |
| ត្រសក់ | C | 12/7/17 | C09172404 | 40 | ផ្សារAEON-C092404 | បេះលើកទី2 |

អត្ថន័យនៃ C09182306:

18: ឆ្នាំ 2018

23: សប្តាហ៍ទី 23

06: ថ្ងៃសៅរ៍

# ឯកសារយោង


1. និពន្ធដោយបណ្ឌិតប្រិនរ៉ូវែលនិងអ្នកស្រីតាក់ អេឡាយឆ្នាំ១៩៩២, សៀវភៅដំណាំបន្លែនៅកម្ពុជា
2. AVRDC 1996, Cultural Practices for Home Garden Crops
3. BSA RBSA Publishers 1990, AVRDC-The World Vegetable Center For more information the Chilli pepper plant Diseases
4. ដំណាំបន្លែនៅកម្ពុជា២០១៦,នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំគម្រោងជំរុញផលិតកម្មស្បៀង សៀវភៅកម្រងរូបភាព ។
5. គម្រោងជំរុញផលិតកម្មស្បៀង២០១៦,សៀវភៅគោលការណ៍ណែនាំវគ្គបណ្តុះបណ្តាលការគ្រប់គ្រងខ្សែសង្វាក់ដំណាំសាកវប្បកម្មសម្រាប់ប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិច នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ ។
6. គម្រោងជំរុញផលិតកម្មស្បៀង២០១៦,បច្ចេកទេសដាំដំណាំនាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំ និងកម្មវិធីវិធានការចម្រុះគ្រប់គ្រងដំណាំ(IPM)ជាតិ, ។
7. គម្រោងជំរុញផលិតកម្មស្បៀង២០១៧,បច្ចេកទេសគ្រប់គ្រងផលិតផលក្រោយពេលប្រមូលលផល
8. អគ្គនាយកកសិកម្ម២០០៩,គោលការណ៍ណែនាំអំពីវិធីសាស្រ្តប្រើប្រាស់ថ្នាំកសិកម្មដើម្បីសុវត្ថិភាពនិងប្រសិទ្ធភាព។
9. នាយកដ្ឋានការពារដំណាំជាភាសាខ្មែរ ២០១៩,សទ្ទានុក្រមសមាសភាពចង្រៃលើដំណាំសំខាន់ៗ
10. បណ្ឌិតជាងហុងនិងលោកបណ្ឌិត ងិនឆាយ ២០១៤,សត្វចង្រៃបំផ្លាញដំណាំសំខាន់ៗនៅកម្ពុជា
11. គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាបបច្ចេកទេសដាំដំណាំបន្លែ (ម្ទេស)។
12. ប្រទេសអូស្រ្តាលីនិងប្រទេសកម្ពុជា២០១៣,សៀវភៅណែនាំសម្រាប់កំណត់អត្តសញ្ញាណសត្វល្អិតចង្រៃសត្វល្អិតមានប្រយោជន៍ លក្ខណៈខុសប្រក្រតី ។
13. ការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើនិងបន្លែស្រស់ផ្នែកសុវត្ថិភាពចំណីអាហារ,២០២២